ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤៩៤ ប្រក.កសក

# ប្រកាស
## ស្តីពី
## ការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តស្ទឹងត្រែង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ២១៩ប្រក.កសក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១.–**

ត្រូវបានបង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តស្ទឹងត្រែង សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើដែលមានទីតាំងស្ថិតនៅក្នុងផ្ទៃរដ្ឋបាលព្រៃឈើស្ទឹងត្រែងនៃខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែង។

**ប្រការ ២.**_

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង ៖

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះ និងអភិវឌ្ឍព្រៃសហគមន៍ឲ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅ ទំនៀមទម្លាប់ និង ជំនឿ សាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាននិងសក្តានុពលព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។

**ប្រការ ៣.**_

តំបន់ព្រៃសហគមន៍ក្នុងខេត្តស្ទឹងត្រែងនៃប្រកាសនេះមាន២(ពីរ)សហគមន៍ព្រៃឈើ ចែកចេញជា២(ពីរ)កន្លែង ដែលមានផ្ទៃដីសរុបចំនួន៩៩៦,៤៤ហិកតា (ប្រាំបួនរយកៅសិបប្រាំមួយហិកតានិងសែសិបបួន) ដូចមានក្នុងផែនទីភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និងជាប្រព័ន្ធខ្សែព្រំបិទជិតកំណត់ដោយចំណុចគោល និងនិយាមកាដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ។

**ប្រការ ៤.**_

ដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។

**ប្រការ ៥.**_

បទប្បញ្ញត្តិទាំងឡាយណាក្នុងក្របខ័ណ្ឌនៃការបង្កើតព្រៃសហគមន៍ខាងលើដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.**_

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្មខេត្តស្ទឹងត្រែង ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី.១០....ខែ.តុលា......ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តស្ទឹងត្រែង
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ១ : ប្រកាសលេខ ...៤៥៤........... ប្រក.កសក ចុះថ្ងៃទី ...១៨... ខែ ...តុលា........ ឆ្នាំ ...២០១៤

# ផែនទីទីតាំងព្រៃសហគមន៍ក្នុងខេត្តស្ទឹងត្រែង



ឧបសម្ព័ន្ធ២ ៖ ភ្ជាប់ប្រកាសលេខ......៤៩៤..........ចុះថ្ងៃទី....១០.....ខែ..តុលា.....ឆ្នាំ២០១៤

## ទីតាំងព្រៃសហគមន៍ក្នុងខេត្តស្ទឹងត្រែង

| ល.រ | ឈ្មោះសហគមន៍ព្រៃឈើ | ផ្ទៃដី (ហិកតា) | ចំណុចនិយាមកាទីតាំងព្រៃសហគមន៍ | | | | ចំនួនភូមិ | ឈ្មោះឃុំ | ឈ្មោះស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|
| ១ | អូរប្ញស្សីកណ្តាល | ៤២,៧៤ | 619541 1477208<br>619560 1477287<br>619323 1477543<br>619354 1477587 | 619296 1477796<br>619541 1477800<br>619569 1477950<br>619967 1477949 | 620002 1477987<br>620002 1477332<br>619977 1477332<br>619868 1477299 | 619791 1477229<br>619715 1477048<br>619651 1477000<br>619651 1477045 | ១ | អូរប្ញស្សីកណ្តាល | សេសាន | ស្ទឹងត្រែង |
| ២ | ព្រៃឱធម្ម | ៩៥៣,៧០ | 672838 1516162<br>673242 1515743<br>673515 1515756<br>673752 1515431<br>674085 1515030<br>674242 1514656 | 673942 1514088<br>673426 1513811<br>672700 1513481<br>672270 1513431<br>671930 1512914 | 670888 1512913<br>670960 1513259<br>670680 1514032<br>670144 1514569<br>669994 1514941 | 669756 1515369<br>669862 1515977<br>670311 1515943<br>670961 1515808<br>672125 1516076 | ១ | តាឡាត | សៀមបូក | ស្ទឹងត្រែង |
| | សរុប | ៩៩៦,៤៤ | | | | | ០២ | ០២ | ០២ | ០២ |


619200
619600
620000
620400
1478000
1477600
1477200
Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 60
0
100
200 m

*សហគមន៍ព្រៃឈើ អូរឫស្សីកណ្តាល ៤២,៧៤ហិកតា*

| | | | |
|---|---|---|---|
| 619541 1477208 | 619296 1477796 | 620002 1477987 | 619791 1477229 |
| 619560 1477287 | 619541 1477800 | 620002 1477332 | 619715 1477048 |
| 619323 1477543 | 619569 1477950 | 619977 1477332 | 619651 1477000 |
| 619354 1477587 | 619967 1477949 | 619868 1477299 | 619651 1477045 |